អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖

- ការនាំចេញរបស់កម្ពុជាទៅថៃ ធ្លាក់ចុះជិតពាក់កណ្តាលក្នុងត្រីមាសទី១ ឆ្នាំ២០២១
- កម្ពុជាក្នុងចំណោមប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ជំរុញកិច្ចសហប្រតិបត្តិការកសិកម្ម
- ប្រៀបធៀបការប្រមូលចំណូលរដ្ឋ ក្នុងខែកុម្ភៈ ឆ្នាំ២០២១ ធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន
- សេដ្ឋកិច្ចកូរ៉េខាងត្បូងកើនឡើងលឿនជាងការរំពឹងទុក នៅក្នុងត្រីមាសទី១ ឆ្នាំ២០២១
- ក្រុមហ៊ុនជាច្រើននៅប្រទេសវៀតណាម បន្ទាបគោលដៅប្រាក់ចំណេញរបស់ខ្លួនក្នុងឆ្នាំ២០២១ បើទោះបីជា ទស្សនវិស័យសេដ្ឋកិច្ចមានភាពល្អប្រសើរក្តី
- ការបំពេញការងាររបស់លោកប្រធានាធិបតីសហរដ្ឋអាមេរិក ទទួលបានសម្លេងគាំទ្រចំនួន៥៣% ជាពិសេសការគាំទ្រលើផែនការហេដ្ឋារចនាសម្ព័ន្ធ
- លោកប្រធានាធិបតី Joe Biden បានដាក់ចេញនូវកម្មវិធីផ្តល់អាហារសម្រាប់កុមារដែលស្ថិតក្នុងគ្រួសារ ដែលមានចំណូលទាបប្រមាណ ៣៤លាននាក់

ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ជី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

ចងក្រង និងបូកសរុបដោយ

- ជីម ប៊ុនធឿន ប្រធានការិយាល័យវិភាគចំណូល-ចំណាយ

# ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

## ការនាំចេញរបស់កម្ពុជាទៅថៃធ្លាក់ចុះជិតពាក់កណ្តាល ក្នុងត្រីមាសទី១ ឆ្នាំ២០២១



*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ២០២១, រូបភាព៖ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ*

ការនាំចេញរបស់ប្រទេសកម្ពុជាទៅប្រទេសថៃបានធ្លាក់ចុះ ៤៨,៩៣% ក្នុងទំហំទឹកប្រាក់នៅត្រឹម៣២៩,៥៤ លានដុល្លារ នៅក្នុងត្រីមាសទី១ ឆ្នាំ២០២១ ដែលថយពីចំនួន៦៤៥,២៣លានដុល្លារ ក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុន នេះបើយោងតាមនាយកដ្ឋានពាណិជ្ជកម្មបរទេសរបស់ថៃ។

ពាណិជ្ជកម្មទ្វេភាគីរវាងព្រះរាជាណាចក្រទាំងពីរមានចំនួន ២,១០ពាន់លានដុល្លារ ក្នុងខែមករា ដល់ខែមីនា ធ្លាក់ចុះ ២១,៣៧% ធៀបនឹង ២,៦៧ពាន់លានដុល្លារ ក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ក្នុងនោះ ប្រទេសកម្ពុជា បាននាំចូល ១,៧៧ពាន់លានដុល្លារ ធ្លាក់ចុះ ១២,៥៧% ធៀបនឹងឆ្នាំមុនដែលមានចំនួន ២,០២ពាន់លានដុល្លារ ដែលនេះមានន័យថា ឱនភាពពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាបានកើនឡើង៤,៥% ពី ១,៣៨ពាន់លានដុល្លារ ក្នុងត្រីមាសទី១ឆ្នាំ២០២០ ដល់ ១,៤៤ពាន់លានដុល្លារក្នុងត្រីមាសទី១ ឆ្នាំ២០២១នេះ។

តាមរយៈអ្នកជំនាញ ការធ្លាក់ចុះយ៉ាងខ្លាំងនៃការនាំចេញទៅកាន់ប្រទេសថៃ គឺដោយសារតែកត្តាសំខាន់ពីរ៖ ការរឹតត្បិតព្រំដែន ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងការជាប់គាំងនៃការធ្លាក់ចុះផលិតកម្មនៅខាងកម្ពុជា។ ទន្ទឹមនឹងនេះ ផលិតផលកសិកម្ម គឺជាការនាំចេញសំខាន់តែមួយគត់ទៅកាន់ប្រទេសថៃនាពេលបច្ចុប្បន្ននេះ ជាពិសេស ជំងឺកូវីដ-១៩ បានកាត់បន្ថយការបញ្ជាទិញទាំងសងខាង៕ *ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ Phnom Penh Post, ចេញផ្សាយថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០២១*

## កម្ពុជាស្ថិតក្នុងចំណោមប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ជំរុញកិច្ចសហប្រតិបត្តិការកសិកម្ម



*ប្រភព៖ Khmer Times ២០២១ រូបភាព៖ MAFF*

ប្រទេសកម្ពុជា និងប្រទេសនានានៅតំបន់អាស៊ីប៉ាស៊ីហ្វិក បានចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាន ដើម្បីជំរុញកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម ជាពិសេសលើការធានាសន្តិសុខស្បៀងប្រកបដោយចីរភាពនៅក្នុងតំបន់។

កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ស្តីពីប្រព័ន្ធស្បៀងអាហារឆ្នាំ២០៣០ ធ្វើឡើងក្រោមប្រធានបទ "ការកសាងឡើងវិញឱ្យកាន់តែប្រសើរ" ("Building Back Better") ដោយមានការសម្របសម្រួលពីលោកស្រី **ម៉ារី ផេជស៊ី** នាយកគ្រប់គ្រងធនាគារពិភពលោកសម្រាប់គោលនយោបាយ និងភាពជាដៃគូ និងមានការចូលរួមពីឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទកម្ពុជា និងសមភាគីមកពីឥណ្ឌូនេស៊ី ឡាវ ម៉ុងហ្គោលី ប៉ាពួញូហ្គីណេ ហ្វីលីពីន វៀតណាម និងទីម័រខាងកើត ក៏ដូចជាតំណាងមកពីអង្គការ FAO លេខាធិការដ្ឋានអាស៊ាន និងអង្គការជាតិ និងអន្តរជាតិបានចូលរួមក្នុងវេទិកានេះ។

ឯកឧត្តម **វេង សាខុន** បានលើកឡើង ពីបញ្ហាប្រឈមមួយចំនួននៅក្នុងវិស័យកសិកម្មនៅប្រទេសកម្ពុជា រួមមានផលិតភាពកសិកម្មទាប និងកង្វះទីផ្សារ។ ជាមួយគ្នានេះ ក្រសួងកំពុងធ្វើការយ៉ាងខ្លាំង ដើម្បីលើកកម្ពស់ផលិតភាពស្រូវដែលមានគុណភាព ក៏ដូចជាដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម តាមរយៈការធ្វើពិពិធកម្មកសិកម្ម ព្រមទាំងពង្រឹងអនាម័យដំណាំ និងភូតគាមអនាម័យ អភិវឌ្ឍវារីវប្បកម្មគ្រប់ទម្រង់សម្រាប់កសិករ និងជំរុញការវិនិយោគ។ ក្នុងឱកាសនោះដែរ ឯកឧត្តមរដ្ឋមន្ត្រីក៏បានបង្ហាញអំពីគម្រោងដែលកំពុងត្រូវបានអនុវត្ត ដើម្បីឆ្លើយតបទៅនឹងការគម្រាមកំហែង ពីវិបត្តិជំងឺកូវីដ-១៩ ក្រោមក្របខ័ណ្ឌពិពិធកម្មកសិកម្មរបស់ប្រទេសកម្ពុជា ដែលគាំទ្រដោយធនាគារពិភពលោក៕

*ដោយ វត្តា វង្សវឌ្ឍនៈ*

*ប្រភព៖ Khmer Times, ចេញផ្សាយថ្ងៃទី២៥ ខែមេសាឆ្នាំ២០២១*

## តារាងប្រចាំសប្តាហ៍៖ ប្រៀបធៀបការប្រមូលចំណូលរដ្ឋក្នុងខែកុម្ភៈ ឆ្នាំ២០២១ ធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន

យោងតាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្ហាញថា៖ ការអនុវត្តលើការប្រមូលចំណូលក្នុងស្រុកសរុប ក្នុងខែកុម្ភៈ ឆ្នាំ២០២១ បានធ្លាក់ចុះជិត ៦% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។

ជាក់ស្តែង នៅក្នុងខែកុម្ភៈ ចំណូលក្នុងប្រទេសសរុបថ្នាក់ជាតិអនុវត្តបាន ៨,៨៩% នៃច្បាប់ហិរញ្ញវត្ថុ ឬ ស្មើនឹង ១ ៧៧១ ប៊ីលានរៀល ដែលធ្លាក់ចុះជិត ៦% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។ ក្នុងនោះដែរ ចំណូលសារពើពន្ធមានចំនួន ១ ៣២៥ ប៊ីលានរៀល ឬធ្លាក់ចុះប្រហែល ៩% ដែលការធ្លាក់ចុះនេះអាចបណ្តាលមកពីកត្តាមួយចំនួន ដូចជា ការធ្លាក់ចុះនូវប្រភពចំណូលពន្ធប្រយោល និងពាណិជ្ជកម្មក្រៅប្រទេស។ ចំណែកឯចំណូលមិនមែនសារពើពន្ធមានចំនួន ៤៤២ ប៊ីលានរៀល គឺកើន ៥% ដែលកំណើននេះបណ្តាលមកពីការប្រមូលពន្ធផលទុននៃទ្រព្យសម្បត្តិរដ្ឋ ផលទុនពីសហគ្រាសសាធារណៈ និងផលទុនពីការគ្រប់គ្រងរដ្ឋបាល។

រីឯ ចំណូលមូលធននៅរក្សាលំនឹង ដែលមានចំនួន ៣,៣៦ ប៊ីលានរៀនក្នុងខែកុម្ភៈ ឆ្នាំ២០២១ ដែលស្មើនឹងខែកុម្ភៈ ឆ្នាំ២០២០។

សរុបជារួម ការធ្លាក់ចុះនូវចំណូលថវិកាជាតិនេះ ត្រូវបានបង្ហាញថា ដោយសារតែការថមថយសកម្មភាពសេដ្ឋកិច្ចក្នុងបរិការណ៍ការរីករាលដាលនៃជំងឺកូវីដ-១៩ និងការអនុវត្តវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល ក៏ដូចជា ការលើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទ សម្រាប់វិស័យទេសចរណ៍ និងពន្ធអប្បបរមាសម្រាប់វិស័យអាកាសចរណ៍ផងដែរ៕

*ដោយ ឈន ហាំ*

| ចំណូល(ប៊ីលានរៀល) | អនុវត្តន៍ | | ច្បាប់ | | ធៀបនឹងច្បាប់ | | កំណើន(%) |
|---|---|---|---|---|---|---|---|
| | Feb-20 | Feb-21 | 2020 | 2021 | Feb-20 | Feb-21 | Feb(2020-21) |
| ចំណូលក្នុងស្រុកសរុបថ្នាក់ជាតិ | 1,883 | 1,771 | 24,093 | 19,927 | 7.82% | 8.89% | -5.94% |
| ១.ចំណូលចរន្ត | 1,880 | 1,768 | 23,899 | 19,706 | 7.86% | 8.97% | -5.96% |
| ក.ចំណូលសារពើពន្ធ | 1,460 | 1,325 | 21,091 | 17,520 | 6.92% | 7.56% | -9.21% |
| ខ.ចំណូលមិនមែនសារពើពន្ធ | 420 | 442 | 2,808 | 2,186 | 14.95% | 20.23% | 5.38% |
| ២.ចំណូលមូលធន | 3 | 3 | 193 | 221 | 1.74% | 1.52% | 0.00% |

*ប្រភព៖ ការអនុវត្តថវិការដ្ឋ ខែធ្នូ ឆ្នាំ២០២០ និងការនុវត្តថវិការដ្ឋ ខែកុម្ភៈ ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១*

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## សេដ្ឋកិច្ចកូរ៉េខាងត្បូង កើនឡើងលឿនជាងការរំពឹងទុកក្នុងត្រីមាសទី១ ឆ្នាំ២០២១



*ប្រភព៖ The Korea Times ២០២១ រូបភាព៖* gettyimagesbank

សេដ្ឋកិច្ចរបស់ប្រទេសកូរ៉េខាងត្បូង បានកើនឡើងក្នុងល្បឿនលឿនជាងការរំពឹងទុកនៅក្នុងត្រីមាសទី១ ឆ្នាំ២០២១ ដែលជាសញ្ញាបង្ហាញថា សេដ្ឋកិច្ចរបស់ប្រទេសនេះ កំពុងឈានជិតដល់កម្រិតមុនការរាតត្បាតនៃជំងឺកូវីដ-១៩ នេះបើយោងតាមធនាគារជាតិកូរ៉េខាងត្បូង។

ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) របស់កូរ៉េខាងត្បូង បានកើនឡើង ១,៨% ក្នុងរយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ផ្អែកតាមមូលដ្ឋានប្រចាំត្រីមាស ផ.ស.ស. របស់ប្រទេសសេដ្ឋកិច្ចធំជាងគេលំដាប់ទី៤ នៅអាស៊ីមួយនេះ មានកំណើន ១,៦% នៅក្នុងត្រីមាសទី១ ឆ្នាំ២០២១ ដែលបានកើនឡើងពី ១,២% នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២០ ដែលកំណើននេះ ត្រូវបានគាំទ្រ

ដោយការកើនឡើងនូវចំណាយឯកជន ឥណទានវិនិយោគ ការគាំទ្រគោលនយោបាយសារពើពន្ធរបស់រដ្ឋាភិបាល និងការស្ទុះងើបឡើងវិញបន្តិចនៃការនាំចេញ។

ធនាគារជាតិកូរ៉េខាងត្បូង បានបញ្ជាក់ទៀតថា កំណើន ផ.ស.ស. ឆ្នាំនេះ ទំនងជាខ្ពស់ជាងការព្យាករណ៍ពីមុនរបស់ខ្លួន និងអាចកើនក្នុងរង្វង់ជាង ៣%។

ទន្ទឹមនឹងនេះ ធនាគារជាតិគ្រោងនឹងបង្ហាញការព្យាករណ៍កំណើនសេដ្ឋកិច្ចថ្មីរបស់ខ្លួនដែលត្រូវបានកែសម្រួលនៅក្នុងខែឧសភាខាងមុខ។ ធនាគារជាតិ បានបញ្ជាក់ថា មានលទ្ធភាពខ្ពស់ដែលអាចបង្កើនទស្សនវិស័យសេដ្ឋកិច្ចរបស់កូរ៉េខាត្បូងតាមរយៈការឆ្លុះបញ្ចាំងនូវការកើនឡើងយ៉ាងឆាប់រហ័សនៃការនាំចេញ និងការវិនិយោគ និងប្រសិទ្ធភាពនៃថវិកាចំណាយបន្ថែមរបស់រដ្ឋាភិបាល ព្រមទាំងការកើនឡើងនូវកញ្ចប់ជំនួយសង្គ្រោះបន្ទាន់នៅសហរដ្ឋអាមេរិកផងដែរ។

ជាមួយគ្នានេះ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក៏បានបង្កើនការព្យាករណ៍របស់ខ្លួននាពេលថ្មីៗនេះផងដែរ អំពីកំណើនសេដ្ឋកិច្ចកូរ៉េខាងត្បូងដល់ ៣,៦%នៅឆ្នាំ២០២១។

សូមបញ្ជាក់ដែរថា សេដ្ឋកិច្ចកូរ៉េខាងត្បូង បានធ្លាក់ចុះខ្លាំងដល់ -១,៣% និង -៣,២% នៅក្នុងត្រីមាសទី១ និងត្រីមាសទី២ រៀងគ្នា មុនពេលកើនឡើងវិញក្នុងអត្រា ២,១% នៅក្នុងត្រីមាសទី៣ និង ១,២% នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២០។ *ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ គេហទំព័រសារព័ត៌មាន The Korea Times, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១*

## ក្រុមហ៊ុនជាច្រើននៅប្រទេសវៀតណាម បន្ទាបគោលដៅប្រាក់ចំណេញរបស់ខ្លួន ក្នុងឆ្នាំ២០២១ បើទោះបីជាទស្សនវិស័យសេដ្ឋកិច្ចមានភាពល្អប្រសើរក្ដី



*ប្រភព៖ Vietnam Plus ២០២១, រូបភាព៖ npcetc.vn*

សេដ្ឋកិច្ចវៀតណាម ត្រូវបានរំពឹងថានឹងមានកំណើនខ្លាំងឡើងវិញនៅឆ្នាំនេះ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ត្រូវបានទប់ស្កាត់។ ទោះជាយ៉ាងនេះក្ដី ក្រុមហ៊ុននៅក្នុងវិស័យមួយចំនួននៅប្រទេសវៀតណាម នៅតែបន្ទាបគោលដៅប្រាក់ចំណេញរបស់ពួកគេ។

ជាក់ស្ដែង យោងតាមក្រុមហ៊ុនសាជីវកម្មមូលបត្រ VNDirect (VNDirect Securities Corporation) បានបង្ហាញថា ប្រាក់ចំណេញសរុបនៃក្រុមហ៊ុនចុះបញ្ជីនៅក្នុងផ្សារភាគហ៊ុនចំនួនបី រួមមាន៖ ក្រុមហ៊ុនផ្សារភាគហ៊ុនហូជីមិញ (Ho Chi Minh Stock Exchange) ក្រុមហ៊ុនផ្សារភាគហ៊ុនហាណូយ (Hanoi Stock Exchange) និងក្រុមហ៊ុនផ្សារភាគហ៊ុន UPCOM (Unlisted Public Company Market)- បានកើនឡើង ១៥,៦% នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២០ ធៀប

នឹងរយៈពេលដូចគ្នា នៅក្នុងឆ្នាំ២០១៩។ ប្រាក់ចំណេញរបស់ក្រុមហ៊ុន ដែលបានរាយនាមក្នុងទីផ្សារភាគហ៊ុន ត្រូវបានប៉ាន់ប្រមាណថា នឹងកើនឡើង ២៣% នៅឆ្នាំ២០២១ ដោយសារតែការរំពឹងទុកនៃការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ច។ ទោះជាយ៉ាងនេះក្តី ក្រុមហ៊ុនជាច្រើនបានកំណត់គោលដៅប្រាក់ចំណេញទាបសម្រាប់ផ្តល់ដល់ម្ចាស់ភាគហ៊ុន ធៀបនឹងគោលដៅឆ្នាំមុន។

ដូចគ្នាដែរ ក្រុមហ៊ុនផ្គត់ផ្គង់ថាមពល Pha Lai Thermal Power JSC (PPC) បានកំណត់គោលដៅប្រាក់ចំណូលសរុបរបស់ខ្លួនប្រហែល ៥,៧ទ្រីលានដុង ក្នុងឆ្នាំ២០២១ ពោលគឺធ្លាក់ចុះ ៣១% ពីឆ្នាំមុន។ ជាលទ្ធផលប្រាក់ចំណេញមុនបង់ពន្ធ នឹងធ្លាក់ចុះ ៦៦% ឬធ្លាក់ចុះដល់ ៤១៥ ប៊ីលានដុង ដែលនេះជាគោលដៅប្រាក់ចំណេញទាបបំផុតចាប់ពីឆ្នាំ២០១៤ បើទោះបីជាកំណើនវិស័យថាមពលបានកើនឡើងខ្លាំងដូចទៅនឹងការរំពឹងទុកក្តី។

ចំណែកឯ ក្រុមហ៊ុនសាជីវកម្ម ៣៦ (G៣៦) បានធ្វើឱ្យម្ចាស់ភាគហ៊ុន និងវិនិយោគិនមានការភ្ញាក់ផ្អើលជាមួយនឹងផែនការប្រាក់ចំណូលដែលមានត្រឹមជាង ១៩ទ្រីលានដុង ប៉ុណ្ណោះ ពោលគឺធ្លាក់ចុះ ១៧,០៣% ធៀបនឹងឆ្នាំមុន និងខាតបង់ទឹកប្រាក់ចំនួន ៦៦ប៊ីលានដុង។ ខណៈនៅក្នុងឆ្នាំ២០២០ បើទោះបីជា G៣៦ បានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីវិបត្តិជំងឺកូវីដ-១៩ ក្តី ក៏ G៣៦ នៅតែសម្រេចបានលទ្ធផលអាជីវកម្មគួរឱ្យពេញចិត្ត ដោយប្រាក់ចំណូលបានកើនឡើងដល់ជាង ២,៣ទ្រីលានដុង ដែលកើនឡើង ២៨,៧%។ ជាលទ្ធផលប្រាក់ចំណេញបន្ទាប់ពីបង់ពន្ធរួចបានកើនឡើង ៨៣,៤% ពោលគឺកើនដល់ ៥៨ប៊ីលានដុង។ សូមបញ្ជាក់ដែរថា ចាប់តាំងពីចុះឈ្មោះធ្វើពាណិជ្ជកម្មនៅលើ UPCOM ក្នុងឆ្នាំ២០១៦ G៣៦ តែងតែទទួលបានប្រាក់ចំណេញ។

ទន្ទឹមនឹងនេះ ក៏មានក្រុមហ៊ុនមួយចំនួន បានទាំងកំណត់គោលដៅប្រាក់ចំណេញអវិជ្ជមានទៀតផង៕

*ដោយ ស៊ិន សុភាព៌*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Vietnam Plus ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### ការបំពេញការងាររបស់លោកប្រធានាធិបតីសហរដ្ឋអាមេរិក ទទួលបានសម្លេងគាំទ្រចំនួន៥៣% ជាពិសេសការគាំទ្រភាគច្រើនលើផែនការហេដ្ឋារចនាសម្ព័ន្ធ



*ប្រភព៖ Carpenters Pittsburgh Training Center 2021, រូបភាព៖ Jonathan Ernst*

យោងតាមការស្ទង់មតិរបស់ "សារព័ត៌មានអតិថិជន និងបណ្តាញអាជីវកម្ម" (CNBC) បានបង្ហាញថា៖ ប្រជាជន

អាមេរិកជាងពាក់កណ្ដាលបានគាំទ្រការអនុវត្តការងាររបស់លោកប្រធានាធិបតីថ្មីនៃសហរដ្ឋអាមេរិក រួមជាមួយការអនុម័តលើសំណើហេដ្ឋារចនាសម្ព័ន្ធដ៏ធំមួយ។

ជាលទ្ធផលនៃការស្ទង់មតិបានបង្ហាញថា ការអនុវត្តការងាររបស់ប្រធានាធិបតីកន្លងមក ទទួលបានសម្លេងនៃការគាំទ្រ៥៣% គឺក្នុងនោះមានមតិគាំទ្រ ៩០% ជាក្រុមអ្នកប្រជាធិបតេយ្យ, ៦១% ក្រុមអ្នកឯករាជ្យ និង ៩%មកពីក្រុមសាធារណរដ្ឋ ខណៈដែល ៣៩% មិនគាំទ្រការអនុវត្តការងាររបស់លោកប្រធានាធិបតី។

លោកប្រធានាធិបតីទទួលបានការគាំទ្រពីការអនុម័តលើកញ្ចប់ថវិកាសម្រាប់ជំនួយសង្គ្រោះកាលពីខែមីនា និងសំណើហេដ្ឋារចនាសម្ព័ន្ធដែលមានទឹកប្រាក់ ២ទ្រីលានដុល្លារ ក្នុងគោលបំណងដើម្បីជួយជំរុញសេដ្ឋកិច្ចក្រោយពីការរាតត្បាតនៃជំងឺកូវីដ-១៩។ ក្នុងនោះដែរ តាមរយៈការស្ទង់មតិបានបញ្ជាក់ថា៖ ប្រជាជនអាមេរិក ៤៦% បានគាំទ្រលើការអនុម័តកញ្ចប់ថវិកានេះ ដែលបានផ្ញើនូវប្រាក់សំណងដោយផ្ទាល់ទៅឲ្យប្រជាជនអាមេរិក និងការធានារ៉ាប់រងភាពគ្មានការងារធ្វើបន្ថែមក្នុងចំណោមគោលនយោបាយផ្សេងទៀត ស្របពេលដែល ប្រជាជន ២៥%មិនគាំទ្រ និង ២៦% មិនមានមតិយោបល់។

ដោយឡែក សម្រាប់ផែនការហេដ្ឋារចនាសម្ព័ន្ធរបស់លោក Joe Biden ដែលមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធផ្នែកដឹកជញ្ជូន ប្រព័ន្ធទឹក បណ្ដាញអ៊ីនធឺណិត និងផលិតកម្ម ក៏ដូចជាការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ ការស្ទង់មតិបានបង្ហាញថា ប្រជាជន៥៩%គាំទ្រ និងបាននិយាយថាផែនការនេះគឺជាគំនិតល្អ រីឯ២១% មិនយល់ស្រប និង១៩%មិនមានមតិ។ ចំណែកឯ មតិឆ្លើយតបតាមក្រុមគណបក្សវិញ បង្ហាញថា ៨៧% នៃអ្នកប្រជាធិបតេយ្យ ៦៨%នៃអ្នកឯករាជ្យ និង២១% នៃអ្នកសាធារណរដ្ឋ គាំទ្រផែនការហេដ្ឋារចនាសម្ព័ន្ធនេះ។

ទន្ទឹមនឹងនេះ ចំពោះការគ្រប់គ្រងជំងឺរាតត្បាតកូវីដ-១៩ ក៏ទទួលបានមតិគាំទ្រចំនួន៦៩% និងការគ្រប់គ្រងសេដ្ឋកិច្ចទទួលបានការគាំទ្រ ៥២%។ ចំពោះការដោះស្រាយលើបញ្ហានៃការបង្រួបបង្រួមប្រទេស ទទួលបានការគាំទ្រពីអ្នកឆ្លើយតប ចំនួន៥២% និង ទំនាក់ទំនងជាតិសាសន៍ ទទួលបាន៤៩%។ ដោយឡែក ការស្ទង់មតិក៏បានបង្ហាញផងដែរថា ប្រជាជនមិនសូវពេញចិត្តនឹងវិធីដែលលោក Biden បានដោះស្រាយទំនាក់ទំនងជាមួយប្រទេសចិន សន្តិសុខព្រំដែន និងអន្តោប្រវេសន៍ ដែលមានអ្នកឆ្លើយតបរហូតដល់ ៨០% ដែលនៅតែជឿថា សហរដ្ឋអាមេរិកមានការបែកបាក់ភាគច្រើន បើទោះបីជាលោក Biden សន្យាថានឹងបង្រួបបង្រួមប្រទេសក៏ដោយ។

សូមបញ្ជាក់ផងដែរថា ការស្ទង់មតិនេះត្រូវបានធ្វើឡើងតាមរយៈការស្ទង់មតិមនុស្សពេញវ័យចំនួន ១ ០០០ នាក់ នៅទូទាំងប្រទេស ចាប់ពីថ្ងៃទី១៧ ដល់ទី២០ ខែមេសា ក្នុងចន្លោះជឿជាក់បូកឬដក ៣,១%៕

*ដោយ សេន ចន្នី*

*ប្រភព៖ គេហទំព័រសារព័ត៌មាន CNBC, ចុះផ្សាយថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២១*

## លោកប្រធានាធិបតី Joe Biden បានដាក់ចេញនូវកម្មវិធីផ្តល់អាហារសម្រាប់កុមារដែលស្ថិតក្នុងគ្រួសារដែលមានចំណូលទាបប្រមាណ ៣៤លាននាក់



*ប្រភព៖ dailymail 2021 រូបភាព៖ TNS*

កាលពីថ្ងៃចន្ទ ទី២៦ រដ្ឋបាលរបស់លោក Joe Biden បានប្រកាសប្រាប់សារព័ត៌មានអំពីកម្មវិធីផ្តល់អាហារដល់កុមារចំនួន ៣៤លាននាក់នារដូវក្តៅនេះ។ កម្មវិធីនេះគឺជាផែនការអាហារដ៏ធំបំផុតមួយនៅក្នុងប្រវត្តិសាស្ត្រអាមេរិក និងជាផ្នែកមួយនៃការជំរុញឱ្យកាន់តែទូលំទូលាយរបស់លោកប្រធានាធិបតី Joe Biden ដើម្បីដោះស្រាយបញ្ហាអសន្តិសុខស្បៀង និងភាពក្រីក្ររបស់កុមារនៅសហរដ្ឋអាមេរិក។

ការពង្រីកកម្មវិធីនេះ ត្រូវបានផ្តួចផ្តើមឡើងដោយក្រសួងកសិកម្ម ដែលផ្តល់ជូនកុមាររហូតដល់ ៣៤លាននាក់ ក្នុងទឹកប្រាក់ចំនួន ៣៧៥ដុល្លារ សម្រាប់កុមារម្នាក់ក្នុងមួយសប្តាហ៍ ដើម្បីទិញស្បៀងអាហាររយៈពេលប្រហែល១០សប្តាហ៍សម្រាប់វិស្សមកាលនារដូវក្តៅ និងដើម្បីចិញ្ចឹមកុមារដែលមានប្រាក់ចំណូលទាប។ គួរបញ្ជាក់ផងដែរ ការចំណាយសម្រាប់កម្មវិធីនេះ គឺយកចេញពីកញ្ចប់ជំនួយសង្គ្រោះក្នុងការប្រយុទ្ធប្រឆាំងការរាតត្បាតនៃជំងឺកូវីដ-១៩ ចំនួន១,៩ទ្រីលានដុល្លារ ដែលត្រូវបានអនុម័តកាលពីក្នុងខែមីនា។ ទន្ទឹមនឹងនេះ រដ្ឋមន្ត្រីក្រសួងកសិកម្ម លោក Tom Vilsack បានមានប្រសាសន៍ថាការពង្រីកនេះ ជាអន្តរាគមន៍ផ្លាស់ប្តូរដំបូងដើម្បីកាត់បន្ថយភាពអត់ឃ្លានរបស់កុមារនៅក្នុងសហរដ្ឋអាមេរិក។

សភាបានផ្តល់ថវិកាដល់កម្មវិធីសម្រាប់រដូវក្តៅឆ្នាំ២០២១ និង២០២២ សម្រាប់កុមារដែលមានអាយុក្រោម ៦ឆ្នាំ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានអត្ថប្រយោជន៍នៅក្នុងកម្មវិធីជំនួយអាហារូបត្ថម្ភបន្ថែម និងកុមារដែលទទួលបានអាហារថ្ងៃត្រង់ដោយឥតគិតថ្លៃ ឬបញ្ចុះតម្លៃ ហើយមានលក្ខណៈគ្រប់គ្រាន់សម្រាប់កម្មវិធីនឹងត្រូវចុះឈ្មោះចូលក្នុងកម្មវិធីអាហាររដូវក្តៅនេះបានដោយស្វ័យប្រវត្តិ។ ឪពុកម្តាយ ឬអាណាព្យាបាល នឹងទទួលបានបណ្ណដែលមានឈ្មោះថា ការផ្ទេរអត្ថប្រយោជន៍អេឡិចត្រូនិកក្នុងពេលជំងឺរាតត្បាត( P-EBT ) ដែលផ្ញើពីទីភ្នាក់ងាររដ្ឋ។

យោងតាមមជ្ឈមណ្ឌលគោលនយោបាយភាពក្រីក្រ និងសង្គម នៃសាកលវិទ្យាល័យកូឡុំបៀបានអោយដឹងថា ក្នុងកំឡុងពេលមានរោគរាតត្បាត អត្រាភាពក្រីក្រកុមារភាពនៅអាមេរិកបានកើនឡើង ៣ ពិន្ទុគោល គឺឈានដល់ ២១,៤%។ ក្នុងនោះ អត្រាភាពក្រីក្រសម្រាប់

កុមារស្បែកខ្មៅ និងកុមារដើមកំណើតនៅប្រទេសទទួលឥទ្ធិពលវប្បធម៌របស់អេស្ប៉ាញ មានកម្រិតទ្វេដង ធៀបនឹងកុមារស្បែកស។ ខណៈអត្រាភាពក្រីក្រនៃកុមារស្បែកសមាន ១២,៣% ភាពក្រីក្រកុមារស្បែកខ្មៅមាន ២៦,៣% និងកុមារដើមកំណើតនៅប្រទេសទទួលឥទ្ធិពលវប្បធម៌របស់អេស្ប៉ាញ មាន ២៧ %។ យោងតាមអង្គការ Save the Children បានប៉ាន់ប្រមាណថាមានកុមារប្រមាណជា ១៧ លាននាក់ កំពុងតស៊ូនឹងភាពអត់ឃ្លាននៅអាមេរិក ដែលមានចំនួន ៦លាននាក់ច្រើនជាងមុនពេលមានជំងឺរាតត្បាត៕

*ដោយ សេន ចន្ទី*

*ប្រភព៖ គេហទំព័រសារព័ត៌មាន daily mail, ចុះផ្សាយថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ ការចុះបញ្ជីរថយន្តថ្មីនៅប្រទេសបារាំង សន្ទស្សន៍ផលិតកម្មគ្រុប Ai និងសន្ទស្សន៍សំណង់គ្រុប Ai របស់ប្រទេសអូស្ត្រាលី ការលក់យានយន្តសរុប និងការបម្រែបម្រួលភាគហ៊ុនប្រេងឆៅ API របស់សហរដ្ឋអាមេរិក ការផ្តល់ប្រាក់កម្ចីវិនិយោគសម្រាប់លំនៅឋាន ចំណូលពន្ធរបស់ប្រទេសអាហ្សង់ទីន ទុនបម្រុងអន្តរជាតិរបស់ប្រទេសកូរ៉េខាងត្បូង តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសបារាំង និងទុនបម្រុងអន្តរជាតិរបស់ប្រទេសចិន៕

ខាងក្រោម គឺជាប្រតិទិនដែលនាយកដ្ឋានស្រាវជ្រាវថវិកានឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

<u>ថ្ងៃចន្ទ ទី០៣ ខែឧសភា ឆ្នាំ២០២១</u>

- ការចុះបញ្ជីរថយន្តថ្មីនៅប្រទេសបារាំង ធៀបនឹងឆ្នាំមុន សម្រាប់ខែមេសា
- សន្ទស្សន៍ផលិតកម្មគ្រុប Ai របស់ប្រទេសអូស្ត្រាលី សម្រាប់ខែមេសា

<u>ថ្ងៃអង្គារ ទី០៤ ខែឧសភា ឆ្នាំ២០២១</u>

- ការលក់យានយន្តសរុបរបស់សហរដ្ឋអាមេរិក សម្រាប់ខែមេសា
- ការផ្តល់ប្រាក់កម្ចីវិនិយោគសម្រាប់លំនៅឋានរបស់ប្រទេសអូស្ត្រាលី សម្រាប់ខែមីនា

<u>ថ្ងៃពុធ ទី០៥ ខែឧសភា ឆ្នាំ២០២១</u>

- ការបម្រែបម្រួលភាគហ៊ុនប្រេងឆៅ API របស់សហរដ្ឋអាមេរិក សម្រាប់ថ្ងៃទី៣០ ខែមេសា
- សន្ទស្សន៍សំណង់គ្រុប Ai របស់ប្រទេសអូស្ត្រាលី សម្រាប់ខែមេសា

<u>ថ្ងៃព្រហស្បតិ៍ ទី០៦ ខែឧសភា ឆ្នាំ២០២១</u>

- ចំណូលពន្ធរបស់ប្រទេសអាហ្សង់ទីន សម្រាប់ខែមេសា
- ទុនបម្រុងអន្តរជាតិរបស់ប្រទេសកូរ៉េខាងត្បូង សម្រាប់ខែមេសា

<u>ថ្ងៃសុក្រ ទី០៧ ខែឧសភា ឆ្នាំ២០២១</u>

- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសបារាំង សម្រាប់ខែមីនា
- ទុនបម្រុងអន្តរជាតិរបស់ប្រទេសចិន សម្រាប់ ខែមេសា